អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចដែលមានសំអាងហេតុស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២

ថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញសេចក្តីសម្រេចដែលមានសំអាងហេតុរបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២។ សេចក្តីសម្រេចនេះចេញ ក្រោយពេលមានការប្រកាសដោយផ្ទាល់មាត់អំពីសេចក្តីសម្រេចស្តីពីការបំបែកិច្ចដំណើរការនីតិវិធី កាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ដែលអាចផ្តល់លទ្ធភាពបន្តធ្វើសវនាការធ្វើនៅថ្ងៃទី ៨ ខែ មេសា ដោយនឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៅពេលក្រោយ។

សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីថ្មីនេះត្រូវបានចេញ បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូល (អ.វ.ត.ក) បានលុបចោលសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដើមនៅក្នុងសំណុំរឿង ០០២ កាលពីថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។ សេចក្តីសម្រេចរបស់ អ.ជ.ត.ក ត្រូវបានសាធារណជន និងអង្គការមិនមែនរដ្ឋាភិបាល លើកយកមកពិភាក្សាយ៉ាងទូលំទូលាយតាមបណ្តាប្រព័ន្ធផ្សព្វផ្សាយ។ ទស្សនៈរបស់ពួកគេមានចំណុចខុសប្លែកពីគ្នា និងរួមមានទាំងការលើកឡើងអំពីសុខភាពរបស់ជនជាប់ចោទ ភាពស្មុគស្មាញនៃការជំនុំជម្រះ ព្រមទាំងការស្នើសុំឲ្យដាក់បញ្ចូលបទចោទប្រកាន់លើអង្គហេតុបន្ថែមទៀត ដូចជាអំពើប្រល័យពូជសាសន៍ ការដ្ឋាន និងទីកន្លែងសម្លាប់មនុស្សផ្សេងៗទៀត ក្រៅពីមន្ទីរ ស-២១ ឬការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ពួកគាត់ទាំងអស់គ្នាសុទ្ធតែប្រាថ្នាចង់ឲ្យការជំនុំជម្រះបញ្ចប់ទៅដោយឆាប់រហ័ស តាមលទ្ធភាពដែលអាចធ្វើទៅបាន។ ដោយសារមូលហេតុនេះហើយទើបជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីប្រកាសព័ត៌មាននេះដោយពន្យល់អំពីបញ្ហាខ្លះៗក្នុងចំណោមបញ្ហានានាដែលពាក់ព័ន្ធ។

អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ទឡ្ហីករណ៍របស់ភាគីទាំងអស់កាលពីខែ កុម្ភៈ និងខែ មីនា ឆ្នាំ ២០១៣។ ជាការច្បាស់លាស់ណាស់ដែលថា បើទោះបីជាភាគីទាំងអស់បានឯកភាពជាគោលការណ៍អំពីការបំបែកសំណុំរឿង ០០២

នៅពេលដែលអង្គជំនុំជម្រះបានសម្រេចធ្វើការបង្គាប់ដើមដំបូងឲ្យបំបែកកិច្ចដំណើរការនីតិវិធីកាលពីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក៏ដោយ ក៏ប៉ុន្តែនៅពេលនេះ មានការជំទាស់ទាំងស្រុង ហើយក៏មានទស្សនៈដែលមិនអាចផ្សះផ្សាគ្នាបានទៀតផង។ គ្មានភាគីណាមួយបានគាំទ្រការដាក់បញ្ចូលការចោទប្រកាន់លើអង្គហេតុបន្ថែម ដែលសាធារណជនបានស្នើសុំនោះឡើយ។ នៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យពិចារណាដោយយកចិត្តទុកដាក់បំផុតលើទឡ្ហីករណ៍របស់ភាគី និងថែមទាំងបានអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដែលនៅក្នុងសេចក្តីសម្រេចនោះបានធ្វើមោឃភាពដីកាសម្រេចដើមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២។

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការបំបែកកិច្ចដំណើរការនីតិវិធីគឺដើម្បីផលប្រយោជន៍នៃយុត្តិធម៌។ បទចោទប្រកាន់ទាំងឡាយដែលមាននៅក្នុងសំណុំរឿង ០០២/០១ នឹងត្រូវកំហិតត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំពីភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលបន្ទាប់ពីតំបន់ផ្សេងៗ (ដំណាក់កាលទី ១ និងទី ២) និងការសម្លាប់ទាហានរបបសាធារណរដ្ឋខ្មែរនៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ភ្លាមៗក្រោយថ្ងៃខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងឆ្នាំ ១៩៧៥។ ទាំងអស់នេះមិនត្រឹមតែមានទំនាក់ទំនងទៅនឹងចំនួនជនរងគ្រោះសំខាន់ៗដ៏ច្រើនសន្ធឹកសន្ធាប់ឡើយ ប៉ុន្តែថែមទាំងបានអនុញ្ញាតឲ្យមានការត្រួតពិនិត្យអំពីការចូលរួមរបស់ជនជាប់ចោទនីមួយៗនៅក្នុងការបង្កើតគោលនយោបាយទាក់ទងនឹងការចោទប្រកាន់ទាំងនេះទៀតផង។ វាក៏រក្សាបាននូវលំដាប់លំដោយពេលវេលាដ៏មានសារៈសំខាន់នៃសំណុំរឿងនេះផងដែរ។

នៅគ្រប់ដំណាក់កាលទាំងអស់ អង្គជំនុំជម្រះសាលាដំបូងបានយល់អំពីភាពស្មុគស្មាញ និងវិសាលភាពនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២/០១ ទាំងមូល។ អង្គជំនុំជម្រះក៏បានយល់ច្បាស់ផងដែរថា នៅពេលដែលពេលវេលាបានកន្លងផុតជាច្រើនខែ ជនជាប់ចោទកាន់តែមិនទំនងជាមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការរហូតដល់ពេលមានការសម្រេចជាស្ថាពរលើការចោទប្រកាន់ទាំងអស់ទៅលើពួកគាត់នោះឡើយ។ប្រសិនបើមិនមានសាលក្រមណាមួយទាល់តែសោះនៅក្នុងសំណុំរឿង ០០២ ទេនោះ ជនរងគ្រោះ និងសាធារណជនច្បាស់ជាអស់សង្ឃឹមយ៉ាងខ្លាំង។ អង្គជំនុំជម្រះបានគណនាឃើញថា ខ្លួននឹងត្រូវការពេលវេលាជាច្រើនខែ ប្រសិនបើពង្រីកវិសាលភាពនៃការជំនុំជម្រះ ដោយដាក់បញ្ចូលមន្ទីរ ស-២១ ទៅតាមសំណើរបស់សហព្រះរាជអាជ្ញានោះ ហើយអង្គជំនុំជម្រះក៏នឹងត្រូវចំណាយពេលវេលារាប់ឆ្នាំដើម្បីបញ្ចប់សវនាការលើដីកាដំណោះស្រាយទាំងមូល ប្រសិនបើធ្វើតាមសំណើរបស់ជនជាប់ចោទ។

អង្គជំនុំជម្រះតុលាការកំពូលបានណែនាំអង្គជំនុំជម្រះសាលាដំបូងឲ្យពិចារណាអំពី "កត្តាពាក់ព័ន្ធ*ទាំងអស់*" នៅពេលសម្រេចថាតើការបំបែកកិច្ចដំណើរការនីតិវិធីគឺជាការសមស្របដែរ ឬយ៉ាងណា។ ជាការពិតជាក់ស្តែងគឺថា អ.វ.ត.ក មានបញ្ហាថវិកាធ្ងន់ធ្ងរដែលធ្វើឱ្យអនាគតរបស់ អ.វ.ត.ក មានភាពមិនច្បាស់លាស់។ នៅមុនពេលចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឲ្យការិយាល័យរដ្ឋបាលស្នើសុំការបញ្ជាក់ពីសំណាក់ភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក ឲ្យមានការធានាអំពីថវិកាដើម្បីអាចឲ្យអង្គជំនុំជម្រះបញ្ចប់សំណុំរឿង ០០២/០១។ រហូតមកទល់នឹងពេលនេះ អង្គជំនុំជម្រះមិនបានទទួលការឆ្លើយតបណាមួយទៅនឹងសំណើនេះឡើយ។ ភាពមិនប្រាកដប្រជានៃស្ថិរភាពថវិកា បញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា និងវ័យជរារបស់ជនជាប់ចោទ ខៀវ សំផន ដែលបញ្ហាទាំងអស់នេះពិតជាមានឥទ្ធិពលទៅលើការសម្រេចមិនធ្វើសវនាការរយៈពេលវែងនិងមិនស្តាប់រាល់អង្គហេតុទាំងអស់នោះឡើយ។

អង្គជំនុំជម្រះតុលាការកំពូលបានផ្តោតការយកចិត្តទុកដាក់អំពីសារៈសំខាន់នៃការសម្រេចថា តើជាការពិត សំណុំរឿង ០០២/០១ នឹងជាការជំនុំជម្រះតែមួយគត់នៅក្នុងសំណុំរឿង ០០២ ដែរឬយ៉ាងណា ហើយប្រសិនបើដូច្នេះ ត្រូវធានាឲ្យបានថា សំណុំរឿងនេះតំណាងឲ្យដីកាដំណោះស្រាយទាំងមូល។ "ភាពជាតំណាង" គឺជាសញ្ញាណមួយដែលសហព្រះរាជអាជ្ញានាំយកមកពីតុលាការអន្តរជាតិដទៃទៀត ដែលមានក្របខណ្ឌគតិយុត្តិខុសគ្នាពីក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងពុំទាន់ត្រូវបានកំណត់អត្ថន័យនៅឡើយ។ ចាប់តាំងពីដើមដំបូង អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សំណុំរឿង ០០២/០១ គឺជាសំណុំរឿងទីមួយក្នុងចំណោមសំណុំរឿងមួយចំនួនទៀត ដោយពិនិត្យអំពីការទទួលខុសត្រូវជាក់លាក់របស់ខ្លួនក្រោមក្របខណ្ឌ អ.វ.ត.ក ដើម្បីសម្រេចលើបទចោទទាំងអស់ប្រឆាំងនឹងជនជាប់ចោទដែលនៅសេសសល់។ ខុសប្លែកពីតុលាការអន្តរជាតិផ្សេងទៀត ទាំងសហព្រះរាជអាជ្ញា ទាំងអង្គជំនុំជម្រះសាលាដំបូងមិនមានសិទ្ធិអំណាចក្នុងការសម្រេចយកផ្នែកណាខ្លះនៃការចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយមកពិចារណា ឬ បោះបង់ចោលមិនពិចាណារផ្នែកណាខ្លះនៃបទចោទប្រកាន់បានឡើយ។

យ៉ាងណាមិញ បន្ទាប់ពីបានទទួលការណែនាំឲ្យពិចារណាអំពីគោលគំនិតនៃភាពជាតំណាង អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចមុនៗរបស់ខ្លួន និងបានកត់សម្គាល់ឃើញថា គ្មានភាគីណាមួយបានឯកភាពអំពីអ្វីដែលគួរត្រូវបានដាក់បន្ថែមទៅក្នុងសំណុំរឿង ០០២/០១ ឡើយ។ អង្គជំនុំជម្រះបានសន្និដ្ឋានថា គ្មានសំណើណាមួយដែលភាគីបានធ្វើ ផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះបង្កើនភាពជាតំណាងនៃសំណុំរឿង ០០២/០១ ដូចដែលអង្គជំនុំជម្រះយល់អំពីសញ្ញាណនោះឡើយ ប៉ុន្តែវានឹងអូសបន្លាយពេលវេលាយ៉ាងយូរដែលជាពេលវេលាចាំបាច់ដើម្បីបញ្ចប់តែផ្នែកដំបូងនៃដីកាដំណោះស្រាយទាំងមូល។

ពេលវេលានៃការបញ្ចប់សវនាការដេញដោលលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ នឹងអាស្រ័យលើកត្តានានា

ដូចជា ពេលវេលាសម្រាប់បញ្ចប់បណ្ដឹងសាទុក្ខណាមួយដែលមាន ស្ថានភាពសុខភាពរបស់ជនជាប់ចោទ និងការបញ្ជាក់ថា បញ្ហាថវិកានឹងមិនប៉ះពាល់ដល់បុគ្គលិកសំខាន់ៗ។

អង្គជំនុំជម្រះសាលាដំបូងបានទទួលការណែនាំឲ្យផ្តល់ផែនការសម្រាប់ការជំនុំជម្រះនៅថ្ងៃខាងមុខ ប្រសិនបើខ្លួនសម្រេចបំបែកដីកាដំណោះស្រាយ។ អង្គជំនុំជម្រះសាលាដំបូងបានភ្ជាប់មកជាមួយនឹងសេចក្តីសម្រេចរបស់ខ្លួននូវផែនការព្រាង ហើយខ្លួននឹងធ្វើកិច្ចប្រជុំរៀបចំសវនាការនៅក្នុងត្រីមាសទីបួនក្នុងឆ្នាំនេះ បន្ទាប់ពីមានសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០១ ដើម្បីទុកឱកាសឲ្យភាគីពិភាក្សាអំពីជំហានបន្ទាប់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត៖ +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh